# ឯកសារសង្ខេបអំពីដៃគូអនុវត្តជាយុទ្ធសាស្ត្រ
# ផ្នែក ការស្តារលទ្ធភាពពលកម្ម

## សង្ខេបគម្រោង

គម្រោងឈ្មោះ៖ «ការដាក់បញ្ចូលចំណេះដឹង និងការអនុវត្តន៍ស្តីពីការព្យាបាលការប្រាស្រ័យទាក់ទងទៅក្នុងសេវា និងកម្លាំងការងាររបស់ប្រទេសកម្ពុជា ដើម្បីគាំទ្រប្រជាជនដែលមានភាពពិបាកក្នុងការទំនាក់ទំនង និងពិបាកក្នុងការលេបអាហារនៅកម្រិតខេត្ត»។

គម្រោងនេះប្រើវគ្គហ្វឹកហ្វឺនការព្យាបាលផ្នែកទំនាក់ទំនង និងការផ្តល់សេវាដើម្បីអភិវឌ្ឍធនធាន ការបញ្ជូន និងទិន្នន័យដែលអាចជាមគ្គុទ្ទេសក៍ណែនាំក្នុងដំណើរការអភិវឌ្ឍន៍វិជ្ជាជីវៈ និងសេវានាពេលអនាគត ។

អ្នកព្យាបាលផ្នែកប្រាស្រ័យទាក់ទងគឺពាក់ព័ន្ធនឹងការវាយតម្លៃ ការធ្វើរោគវិនិច្ឆ័យ ការព្យាបាល និងការគាំទ្រដល់អ្នកដែលមានការលំបាកផ្នែកទំនាក់ទំនងនិងការលេបអាហារ។ អ្នកព្យាបាលផ្នែកប្រាស្រ័យទាក់ទងគឺជាអ្នកដែលត្រូវបានទទួលស្គាល់ថាជាអ្នកមានវិជ្ជាជីវៈផ្នែកស្តារលទ្ធភាពពលកម្ម ដែលអ្នកទាំងនោះអាចធ្វើការវាយតម្លៃ ការអន្តរាគមន៍ និងការគាំទ្រប្រកបដោយបរិយាបន្នដល់កុមារ និងមនុស្សពេញវ័យដែលមានការលំបាកផ្នែកទំនាក់ទំនង និងការលេបអាហារ។

តាមការប៉ាន់ស្មានគឺមានប្រជាជនកម្ពុជាចំនួន ៦០០.០០០នាក់ ដែលមានការលំបាកផ្នែកប្រាស្រ័យទាកទង ឬការលេបអាហារ មានន័យថា យ៉ាងហោចណាស់១នាក់ក្នុងចំណោម២៥នាក់ បានទទួលផលពីការព្យាបាលផ្នែកប្រាស្រ័យទាក់ទងស្មើនឹង៤ភាគរយនៃប្រជាជនសរុបនៅកម្ពុជា(អង្គការ OIC Cambodia ឆ្នាំ ២០១៣)។ កម្ពុជាមិនទាន់មានកម្មវិធីសិក្សាផ្នែកប្រាស្រ័យទាក់ទងនៅមហាវិទ្យាល័យទេ ហើយក៏មានការខ្វះខាតជាខ្លាំងសម្រាប់សេវាព្យាបាលផ្នែកនេះផងដែរ។ ហេតុដូច្នេះហើយទើបបុគ្គលិកសិក្សា អ្នកធ្វើការក្នុងវិស័យសុខាភិបាល និងអ្នកធ្វើការក្នុងផ្នែកពិការភាពមានជំនាញនិងការយល់ដឹងលើផ្នែកនេះមានកម្រិតទាបនៅឡើយ ក្នុងការជួយនិងធ្វើបរិយាបន្នអ្នកដែលមានការលំបាកផ្នែកប្រាស្រ័យទាក់ទង និងការលេបអាហារទៅគ្រប់សកម្មភាពសង្គម ដែលជាលទ្ធផលពួកគេត្រូវបានរើសអើង មិនទទួលបានការអប់រំ មិនបានធ្វើការ និងបាត់បង់ឱកាសក្នុងសង្គម និងមានសុខភាពទន់ខ្សោយជាងជនដែលមិនមានពិការភាព។

នាពេលបច្ចុប្បន្ននេះ សេវាព្យាបាលផ្នែកប្រាស្រ័យទាក់ទងនៅកម្ពុជាពិតជានៅមានកម្រិតនៅឡើយ ការព្យាបាលមានតិចតួចនៅទីក្រុងភ្នំពេញដែលដំណើរការដោយវិស័យឯកជន។ នៅក្នុងមន្ទីរពេទ្យរដ្ឋ ឬមណ្ឌលស្តារក្រៅពីភ្នំពេញ មិនមានសេវាព្យាបាលផ្នែកប្រាស្រ័យទាក់ទង ឬអ្នកឯកទេសនោះទេ។ នេះហើយជាមូលហេតុដែលធ្វើឱ្យប្រជាជនខ្មែរដែលមានការលំបាកផ្នែកប្រាស្រ័យទាកទង ឬការលេបអាហារ មិនអាចទទួលបានការព្យាបាល។ ប្រជាជនកម្ពុជាភាគច្រើនដែលមានការលំបាកក្នុងការទំនាក់ទំនង គឺពឹងផ្អែកតែលើការគាំទ្រពីសហគមន៍ និងគ្រួសារ ជាមួយនឹងសេវាសាធារណៈ ដែលមានកម្រិត (Net et al 2023)។ ភាពមិនស៊ីសង្វាក់គ្នាពីតម្រូវការ និងលទ្ធភាពទទួលបានសេវានេះ ទាមទាឱ្យមានការវិនិយោគដ៏សំខាន់ ដើម្បីបង្កើតសេវាព្យាបាលផ្នែកប្រាស្រ័យទាក់ទង និងមានបុគ្គលិកគ្រប់គ្រាន់ឆ្លើយតបទៅនឹងបរិបទឬតម្រូវការសហគមន៍ ។

**លទ្ធផលរំពឹងទុករបស់គម្រោង**

លទ្ធផលគម្រោងទី១៖ បង្កើតឱ្យមានធនធាន និងអ្នកព្យាបាលផ្នែកប្រាស្រ័យទាក់ទងដែលជាជនជាតិខ្មែរ

លទ្ធផលគម្រោងទី២៖ សម្របសម្រួលក្នុងការបង្កើតឱ្យមានសេវាព្យាបាលផ្នែកប្រាស្រ័យទាក់ទងថ្នាក់ខេត្តនៅក្នុងប្រព័ន្ធរបស់រដ្ឋាភិបាល ដើម្បីកំណត់អត្តសញ្ញាណ និង គាំទ្រដល់អ្នកដែលមានការលំបាកក្នុងការប្រស្រ័យទាក់ទងនិងការលេបអាហារ។

លទ្ធផលគម្រោងទី៣៖ បង្កើត និងប្រើប្រាស់មូលដ្ឋាន ទិន្នន័យសម្រាប់តម្រូវការចាំបាច់ និងសេវាផ្នែកប្រាស្រ័យទាក់ទងនៅកម្ពុជា។

**សកម្មភាពសំខាន់ៗ**

**១. បណ្តុះបណ្តាលធនធាន និងអ្នកព្យាបាលប្រាស្រ័យទាក់ទង**

- បង្កើតក្របខណ្ឌសមត្ថភាព សម្រាប់ការព្យាបាលផ្នែកប្រាស្រ័យទាក់ទងនៅកម្ពុជា
- បង្កើត និងផ្តល់កម្មវិធីបណ្តុះបណ្តាល លើផ្នែកការព្យាបាលប្រាស្រ័យទាក់ទង៖នៅមន្ទីរពេទ្យ (កម្រិត២) និងនៅមណ្ឌលសុខភាពនិងសហគមន៍ (កម្រិត១)
- ការចងជាបណ្តាញ ការបង្វឹក និងការផ្តល់ឱកាសអភិវឌ្ឍវិជ្ជាជីវៈសម្រាប់បុគ្គលិកសុខាភិបាល និងបុគ្គលិកស្តារលទ្ធភាពពលកម្ម ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាល

**២. សេវាព្យាបាលផ្នែកប្រាស្រ័យទាក់ទង**

- សាកល្បងសេវាព្យាបាលផ្នែកប្រាស្រ័យទាក់ទងនៅក្នុងមន្ទីរពេទ្យ ឬក្នុងមណ្ឌលស្តារ សម្រាប់ខេត្តគោលដៅ

- ផ្តល់ការវាយតម្លៃទៅលើការព្យាបាលការប្រាស្រ័យទាក់ទង និង សេវាព្យាបាលដែលមានដែនកំណត់ ការបញ្ជូន និងការអនុវត្តន៍ការព្យាបាលការប្រាស្រ័យទាក់ទងដល់ក្រុមទ្រទ្រង់អាណាព្យាបាល ព្រមទាំងយុទ្ធនាការលើកកម្ពស់ការយល់ដឹងនៅតាមសហគមន៍
- ស្វែងរកមតិគាំទ្រសម្រាប់ការដាក់បញ្ចូលនូវសេវា និងការបញ្ជូនអ្នកដែលត្រូវការសេវា ទៅក្នុងមន្ទីរពេទ្យ មណ្ឌលស្តារលទ្ធភាពពលកម្ម និងប្រព័ន្ធអប់រំ

**៣. ការកសាងមូលដ្ឋាននៃការព្យាបាលផ្នែកប្រាស្រ័យទាក់ទង**

- កសាងមូលដ្ឋាន៖ ធ្វើការស្រាវជ្រាវពីតម្រូវការ ការផ្តល់សេវា និង អ្នកព្យាបាលផ្នែកប្រាស្រ័យទាក់ទងនៅកម្ពុជា
- ធ្វើការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីបណ្តុះបណ្តាលកម្រិត១ និង កម្រិត២ និងការសាកល្បងលើសេវាព្យាបាលផ្នែកប្រាស្រ័យទាក់ទង
- ធ្វើការចែករំលែកពីការស្រាវជ្រាវដើម្បីអភិវឌ្ឍវិជ្ជាជីវៈការព្យាបាលផ្នែកប្រាស្រ័យទាក់ទង នៅកម្រិតមូលដ្ឋាន និងអន្តរជាតិ

**អ្នកទទួលផល**

**អ្នកទទួលផលដោយផ្ទាល់**

- បង្កើតឱ្យមានអ្នកធ្វើការលើផ្នែកស្តារលទ្ធភាពពលកម្មកាយសម្បទាក្នុងវគ្គបណ្តុះបណ្តាលកម្រិត២ចំនួន១៥នាក់ (អ្នកចូលរួមមកពីមន្ទីរសុខាភិបាល ឬពេទ្យបង្អែក បុគ្គលិកមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងបុគ្គលិកស្តារដែលមកពីអង្គការនានា) ពីខេត្តគោលដៅ
- មានអ្នកចូលរួមវគ្គបណ្តុះបណ្តាលកម្រិត១ចំនួន២៤នាក់ជាកម្រិតសហគន៍ ដូចជា បុគ្គលិកមណ្ឌលសុខភាព គណកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត (គ.ក.ស.ក) គ្រូបង្រៀន ក្រុមទ្រទ្រង់សុខភាពភូមិ ភ្នាក់ងារសុខាភិបាល អង្គការតំណាងជនមានពិការភាព ការស្តារលទ្ធភាពពលកម្មកាយសម្បទាតាមសហគមន៍ ដែល ចេញពីខេត្តគោលដៅទាំងពីរ
- អ្នកដែលមានការលំបាកផ្នែកប្រាស្រ័យទាក់ទង និងលេបអាហារចំនួន៤០នាក់បានទទួលការព្យា បាលពីអ្នកមានជំនាញចំនួន២នាក់
- កុមារ១០០នាក់ត្រូវបានកំណត់អត្តសញ្ញាណ និងទទួលការប្រឹក្សាពីអ្នកប្រឹក្សា២រូបពីខេត្តគោលដៅទាំងពីរ (កំណត់អត្តសញ្ញាណ ការបញ្ជូន និងការជួយជាមូលដ្ឋាន)
- អាណាព្យាបាលចំនួន២៤នាក់បានទទួលពត៌មាន និងរបៀបក្នុងការជួយការអភិវឌ្ឍន៍ផ្នែកទំនាក់ទំនងដល់កុមារតាមរយៈក្រុមទ្រទ្រង់ឪពុកម្តាយ

- សាកល្បងឱ្យមានកន្លែងព្យាបាលពីរកន្លែង (សេវាព្យាបាលជាក់លាក់) សម្រាប់ផ្តល់ការព្យាបាលផ្នែកទំនាក់ទំ នង នៅក្នុងខេត្តគោលដៅ
- សាកល្បងឱ្យមានកន្លែងព្យាបាលពីរកន្លែង (សំដៅដល់ការកំណត់អត្តសញ្ញាណ ការបញ្ជូន និងការជួយជាមូល ដ្ឋាន) នៅក្នុងខេត្តគោលដៅ ។

**អ្នកទទួលផលដោយប្រយោល**

- មនុស្សដែលមានការលំបាកក្នុងការប្រាស្រ័យទាក់ទងចំនួន៤០០នាក់ និងគ្រួសាររបស់ពួកគេដែលកំពុងរស់នៅក្នុង តំបន់គោលដៅ នឹងទទួលបានការអន្តរាគមន៍លើការព្យាបាល ឬជាការគាំទ្រផ្នែកប្រឹក្សាពីអ្នកដែលបានបណ្តុះ បណ្តាលនៅក្នុងខេត្ត ។

**តំបន់គោលដៅ**

គម្រោងនេះនឹងអនុវត្តនៅខេត្តកំពង់ស្ពឺ និងខេត្តក្រចេះ (គ្របដណ្តប់គ្រប់ស្រុកទាំងអស់)
ភ្នំពេញជាទីតាំងដែលគម្រោងអនុវត្តសកម្មភាពថ្នាក់ជាតិ (សហការដៃគូរជាមួយ មន្ទីរពេទ្យកុមារជាតិ និងសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល) ។

**ដៃគូអនុវត្តគម្រោង**

**មន្ទីរពេទ្យកុមារជាតិ** (NPH) នឹងផ្តល់ធាតុចូល និងផ្តល់ការប្រឹក្សាការព្យាបាលប្រាស្រ័យទាក់ទងនៅពេលមានការតាក់តែង ឬការផ្តល់សេវាទាក់ទងនឹងកម្មវិធីកម្លាំងនៃអ្នកព្យាបាលផ្នែកប្រាស្រ័យទាក់ទង និងក្របខណ្ឌ**សមត្ថ**ភាព (Competency Framework) ក្នុងពេល១២ខែនៃការអនុវត្តន៍។

**សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល** នឹងស្វែងរកភាពជាដៃគូរជាផ្លូវការសម្រាប់បង្កើតឱ្យមានអ្នកព្យាបាលផ្នែក ប្រាស្រ័យទាក់ទងនៅសាកលវិទ្យាល័យព្រមទាំងផ្សាភ្ជាប់បុគ្គលិកសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដែលជាផ្នែក មួយនៃការអភិវឌ្ឍន៍ធនធាន និងជាកក្តាជំរុញ ដើម្បីអនុញ្ញាតឱ្យធនធាន និងការបណ្តុះបណ្តាល ត្រូវបានទទួលស្គាល់ពេញ សិទ្ធិនៅក្នុងការងារស្តារលទ្ធភាពពលកម្ម ជា ផ្លូវការនាពេលអនាគត។

**រយៈពេលអនុវត្តគម្រោង**

ចាប់ពីខែមករា ឆ្នាំ២០២៤ ដល់ខែមិថុនា ឆ្នាំ២០២៧

| ព័ត៌មានទំនាក់ទំនង | |
|---|---|
| អង្គការ OIC Cambodia<br>លោក ឃាល លាង<br>នាយិការប្រតិបត្តិ<br>ទូរស័ព្ទលេខ៖ (៨៥៥) ៩២ ៥០២ ៩១១<br>អ៊ីម៉ែល៖ leang@oiccambodia.org | កម្មវិធី ACCESS 2<br>វេជ្ជបណ្ឌិត ជូ វិវឌ្ឍន៍<br>ប្រធានផ្នែកពិការភាព និងស្តារលទ្ធភាពពលកម្ម<br>ទូរស័ព្ទលេខ៖ (៨៥៥) ១២ ៩១៥ ៦៧៤<br>អ៊ីម៉ែល៖ Vivath.Chou@access2cambodia.org |

គម្រោងនេះ ឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីសេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2)។

ខែមីនា ឆ្នាំ២០២៤